# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៣៥៧៤ ព.ណ...ក.៣

ថ្ងៃអង្គារ ៨រោច ខែអស្សុជ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ពាណិជ្ជករ អាជីវករ ឲ្យបានជ្រាបថា៖ គណៈកម្មការរៀបចំពិព័រណ៍ នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ប្រទេសចិន នឹងរៀបចំព្រឹត្តិការណ៍ "ពិព័រណ៍កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង" ចាប់ពីថ្ងៃទី២៣ ដល់ ២៧ ខែវិច្ឆិកា ឆ្នាំ ២០១៨។ ព្រឹត្តិការណ៍នេះ នឹងត្រូវរៀបចំដោយមានការចូលរួមពីបណ្តាសហគ្រាស និងក្រុមហ៊ុននានា មកពីប្រទេសដែលស្ថិតនៅក្នុងអនុតំបន់ទន្លេមេគង្គ ដោយដាក់តាំងបង្ហាញនូវផលិតផលចម្រុះ និងគម្រោងវិនិយោគនានាជាច្រើនទៀត។ គណៈកម្មការរៀបចំពិព័រណ៍ បានផ្តល់ស្តង់ចំនួន ១៥ស្តង់ដល់កម្ពុជាក្នុងតម្លៃតែ ៥០០យ័ន ក្នុងមួយស្តង់។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញពាណិជ្ជករ អាជីវករ ជាម្ចាស់ក្រុមហ៊ុន និងសហគ្រាសទាំងអស់ ដែលមានបំណងចូលរួមផ្សព្វផ្សាយពីផលិតផលរបស់ខ្លួន ឬស្វែងរកដៃគូពាណិជ្ជកម្មក្នុងពិព័រណ៍នេះ សូមមកទាក់ទង និងបំពេញបែបបទនៅនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយភ្ជាប់មកជាមួយនូវពាក្យស្នើសុំចូលរួម និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ក្រសួងពាណិជ្ជកម្ម សូមរក្សាសិទ្ធិផ្តល់អាទិភាពជូនពាណិជ្ជករ អាជីវករ ដែលអញ្ជើញមកទាក់ទងបានមុន។

ព័ត៌មានបន្ថែម សូមទាក់ទងជាមួយនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងនៅជាន់ទី២ នៃអគារទីស្តីការក្រសួងពាណិជ្ជកម្ម ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។


ទូរស័ព្ទទាក់ទង៖ ០៨៦ ៣៣៣ ៩៣៣ ឬ ០១៧ ៧៥៩ ៥៦៧

០៩៥ ៩២៩ ១៩២ ឬ ០១៧ ៥៥៩ ២៧៧

អាសយដ្ឋានអ៊ីមែល៖ sorn_pitou@yahoo.com ឬ vannameass@yahoo.com

saraysin@yahoo.com ឬ vithoit@yahoo.com


សូមអរគុណ

**KINGDOM OF CAMBODIA**

**Nation - Religion - King**

**Ministry of Commerce**

N°3574MOC.D./.EA

Phnom Penh, 02 October, 2018

# ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform the traders and businessmen that the Organizing Committee of Lancang-Mekong Cooperation Exposition will organize the "Lancang-Mekong Cooperation Exposition (LMCE)" from 23-27 November 2018 at Kunming City, Yunnan Province, P.R of China. This event will be attended by companies and SMEs from GMS countries in region to showcase various mixed products and investment projects. The organizer committee will provide Cambodia 15 booths with a renting rate of 500 yuan per booth.

Therefore, the Ministry of Commerce has the honor to invite all the traders and businessmen who wish to disseminate their products or to look for trade partners in this event, please contact and register at Department of Exhibition Affairs, General Directorate of Trade Promotion, Ministry of Commerce by attaching with application form and other related documents from now until 05th November 2018. The Ministry of Commerce reserves the right to give priority to the "First come, first served" applicants.

For further information, please contact the Department of Exhibitions Affairs, General Directorate of Trade Promotion on the 2nd floor of the MoC Main building, Lot No. 19-61 Russian Federation Blvd, Phum Toek Thla, Sangkat Toek Thla, Khan Sen Sok, Phnom Penh.

Tel: 086 333 933 / 017 759 567
095 929 192 / 017 555 799

E-mail: sorn_pitou@yahoo.com / vannameass@yahoo.com
saraysin@yahoo.com / vitholt@yahoo.com

Thank you!